# L.A. Care Medicare Plus (HMO D-SNP) សន្លឹកសំណួរដែលចោទសួរញឹកញាប់



LIBERTY មានចំណាប់អារម្មណ៍ក្នុងការកែលម្អលទ្ធផលសុខភាពមាត់របស់ ប្រជាពលរដ្ឋដែលមានចំណូលទាបផ្សេងៗពីគ្នា។

1. **តើអត្ថប្រយោជន៍ធ្មេញរបស់ L.A. Care Medicare Plus នឹងចូលជាធរមាននៅពេលណា?**
   អត្ថប្រយោជន៍នេះនឹងចូលជាធរមានចាប់ពីថ្ងៃទី 1 ខែមករា ឆ្នាំ 2024។

2. **តើនរណាជា LIBERTY dental?**
   LIBERTY គឺជាសាជីវកម្មអត្ថប្រយោជន៍ទន្តសាស្ត្រដែលគ្រប់គ្រងជាលក្ខណៈឯកជន ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ 2001។ LIBERTY បានកសាងកេរ្តិ៍ឈ្មោះដ៏រឹងមាំតាមរយៈការបំពេញតាម និងលើសពីការរំពឹងទុករបស់អតិថិជន អ្នកផ្តល់សេវា និងការរំពឹងទុករបស់សមាជិក ដែលអនុញ្ញាតឱ្យយើងរក្សាបានភាពស្មោះត្រង់របស់អតិថិជនស្ថិតនៅជាមួយយើងលើសពី 99%។

3. **តើអ្វីគឺជាបណ្តាញអង្គការអ្នកផ្តល់សេវាពិសេស (EPO)?**
   បណ្តាញអង្គការអ្នកផ្តល់សេវាពិសេស (Exclusive Provider Organization, EPO) របស់ LIBERTY គឺជាជម្រើសអត្ថប្រយោជន៍ Medicare រដ្ឋកាលីហ្វ័រញ៉ាទាំងទ្វេ។

4. **តើអត្ថប្រយោជន៍ទាំងនេះខុសគ្នាពីអ្វីដែល Medi-Cal ផ្តល់ជូនយ៉ាងដូចម្តេច?**
   L.A. Care Medicare Plus (HMO D-SNP) កំពុងផ្តល់អត្ថប្រយោជន៍បន្ថែមដល់សមាជិក និងលើសពីអត្ថប្រយោជន៍ធ្មេញ Medi-Cal ។
   ការសម្របសម្រួលអត្ថប្រយោជន៍នឹងត្រូវបានបង្កើតឡើងដើម្បីធានាថាសមាជិកទទួលបានសិទ្ធិទទួលបានទាំងអត្ថប្រយោជន៍ Medicare និង Medi-Cal របស់ពួកគេ។

5. **តើសមាជិកត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ DentiCal (Medi-Cal) បន្ទាប់ពីអស់អត្ថប្រយោជន៍ LIBERTY របស់ពួកគេដែរឬទេ ឬតើសមាជិកនឹងតម្រូវឱ្យអស់អត្ថប្រយោជន៍ DentiCal របស់ពួកគេជាមុនសិន មុននឹងប្រើប្រាស់ LIBERTY Dental?** អ្នកផ្តល់សេវានឹងចេញវិក្កយបត្រទៅ LIBERTY ជាមុនសិន (អ្នកបង់ប្រាក់ចម្បង)។ Denti-Cal គឺជាអ្នកបង់ប្រាក់បន្ទាប់បន្សំ ឬជាជម្រើសចុងក្រោយ។ ប្រសិនបើអត្ថប្រយោជន៍បន្ថែមត្រូវបានផ្តល់ជូន និងរ៉ាប់រងដោយ Denti-Cal អ្នកផ្តល់សេវាត្រូវតែដាក់ពាក្យបណ្តឹងសំណងសម្រាប់សេវាកម្មទាំងនេះដោយផ្ទាល់ទៅកាន់ Denti-Cal។

6. **តើសមាជិកនឹងត្រូវបានចេញប័ណ្ណទន្តសាស្ត្រដាច់ដោយឡែក មួយដើម្បីទទួលអត្ថប្រយោជន៍ដែរឬទេ?**
   អត់នោះទេ។ ប័ណ្ណ ID ទន្តសាស្ត្រដាច់ដោយឡែកនឹងមិនត្រូវបានផ្តល់ជូនឡើយ។ សមាជិកទាំងឡាយត្រូវបានណែនាំឱ្យបង្ហាញប័ណ្ណ LA Care ID និងប័ណ្ណ ID Medicaid (Medi-Cal) ក្នុងអំឡុងពេលណាត់ពិគ្រោះរបស់ពួកគេ។

7. **តើសមាជិកត្រូវមានការបញ្ជូនបន្តទៅជួបអ្នកឯកទេសទេ?**
   អត់ទេ។ ការបញ្ជូនបន្តមិនត្រូវបានតម្រូវនៅក្នុងគម្រោងនេះទេ។

**8. តើសមាជិកនឹងទទួលបានការអនុញ្ញាតជាមុនដោយរបៀបណា?**

នៅពេលដែលការិយាល័យដាក់ពាក្យស្នើសុំការអនុញ្ញាតជាមុន
សមាជិកនឹងទទួលបានច្បាប់ចម្លងនៃសេចក្ដីសម្រេចចុងក្រោយមួយច្បាប់។ សមាជិកក៏អាចហៅទូរស័ព្ទទៅ LIBERTY
ដើម្បីទទួលបានស្ថានភាពនៃការអនុញ្ញាត។

**9. តើសមាជិកត្រូវចាត់តាំងឱ្យទៅទន្តពេទ្យ ឬការិយាល័យទន្តសាស្ត្រដែរឬទេ?**

ការចាត់តាំងគឺមិនតម្រូវនោះទេ ប៉ុន្តែសមាជិកត្រូវតែជួបជាមួយអ្នកផ្ដល់សេវា LIBERTY/Denti-cal នៅក្នុងបណ្ដាញ។

**10. តើសមាជិកអាចរក្សាអ្នកផ្ដល់សេវាទន្តសាស្ត្រដូចគ្នារបស់ពួកគេនៅក្រោម Denti-Cal បានដែរឬទេ?**

បណ្ដាញជម្រើសអត្ថប្រយោជន៍ Medicare រដ្ឋកាលីហ្វ័រញ៉ាទាំងទ្វេ របស់ LIBERTY ជាផ្នែកនៃបណ្ដាញអ្នកចូលរួម Medi-Cal។ អ្នកផ្ដល់សេវាទាំងអស់ដែលមានក្នុងបញ្ជីឈ្មោះគឺជាអ្នកផ្ដល់សេវានៃ LIBERTY + Denti-Cal។ ប្រសិនបើអ្នកផ្ដល់សេវា Denti-Cal មិនត្រូវបានរាយក្នុងបណ្ដាញ LIBERTY សមាជិកមានជម្រើសក្នុងការតែងតាំងទន្តពេទ្យនៅទីនេះ៖
**www.libertydentalplan.com/lacaremedicare**

**11. តើការដាំធ្មេញនឹងត្រូវបានរ៉ាប់រងដោយ LIBERTY dental ដែរឬទេ?**

អត់ទេ ការដាំធ្មេញមិនមែនជាអត្ថប្រយោជន៍ដែលរ៉ាប់រងនោះទេ។

**12. តើការរ៉ាប់រងលើធ្មេញដាក់ជំនួសសម្រាប់គម្រោងនេះជាអ្វី?**

គោលការណ៍ណែនាំអំពីការរ៉ាប់រងលើធ្មេញដាក់ជំនួសនឹងស្ថិតនៅក្រោម Denti-cal។

សម្រាប់ព័ត៌មានបន្ថែមអំពីអត្ថប្រយោជន៍ Denti-Cal សូមទាក់ទងទៅកម្មវិធី Medi-Cal Dental របស់រដ្ឋ
ដើម្បីស្នើសុំការរ៉ាប់រងតាមរយៈ៖ Smile, California PH៖ **1-800-322-6384**
**https://smilecalifornia.org/contact-us/**

**13. តើខ្ញុំត្រូវបង់ថ្លៃប៉ុន្មាន?**

អ្នកនឹងចំណាយ $0 សម្រាប់សេវាដែលរ៉ាប់រង។

**14. ចុះប្រសិនបើសមាជិកម្នាក់មានគម្រោងទន្តសាស្ត្រផ្ទាល់ខ្លួនផ្សេងទៀត?**
**ពេលខ្លះអ្នកទទួលអត្ថប្រយោជន៍នឹងទិញគម្រោងទន្តសាស្ត្រ ឬចក្ខុវិស័យឯកជន ដើម្បីកាត់បន្ថយ ឬលុបបំបាត់ចំណែកនៃតម្លៃចំណាយរបស់ពួកគេ។ តើការសម្របសម្រួលនៃអត្ថប្រយោជន៍នឹងកើតឡើងយ៉ាងដូចម្ដេច?**

ប្រសិនបើសមាជិកមានគម្រោងផ្ទាល់ខ្លួន ក្រឹតក្រមនោះនឹងក្លាយជាបឋម ហើយ Medicare ជាបន្ទាប់បន្សំ។

**15. តើខ្ញុំអាចទទួលបានព័ត៌មានអំពីអ្វីដែលត្រូវបានរ៉ាប់រងនៅក្រោមគម្រោងនេះដោយរបៀបណា?**

សម្រាប់ព័ត៌មានបន្ថែមអំពីអត្ថប្រយោជន៍ផ្នែកទន្តសាស្ត្រ សូមទូរស័ព្ទទៅកាន់ខ្សែទូរស័ព្ទដោយឥតគិតថ្លៃរបស់ LIBERTY តាមរយៈ៖
**1-855-552-8243** TTY 1-800-735-2922 ឬចូលទៅកាន់
**https://client.libertydentalplan.com/lacaremedicare**